# ប្រភពនិងហេតុដែលនាំអោយមានអំពើបាប

## The Origin and Cause of Sin

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

## *គំនិតផ្សេងៗស្តីពីប្រភពនិងហេតុដែលនាំឱ្យមានបាប*

លទ្ធិម៉ាកនិយម (Marxism) លទ្ធិកុម្មុយនិស្តនិយម (Communism) បានផ្តល់នូវគំនិតមួយក្នុងអំឡុងសតវត្សរ៍ទី២០ស្តីពីអ្វីទៅជាអំពើបាបហើយអ្វីដែលបណ្តាលឱ្យមានអំពើបាប។ ក្រុមទស្សនវិជ្ជាទាំងនេះបង្រៀនថា " អំពើបាបបណ្តាលមកពីគ្មានសមភាពខាងសេដ្ឋកិច្ច និងការប្រកួតប្រជែងខាងផ្នែកសេដ្ឋកិច្ចនេះ"។ គំនិតមួយផ្សេងទៀតនិយាយថា "មនុស្សបានវិវត្តចេញពីសត្វផ្សេងៗ ហើយសភាវគតិរបស់សត្វក៏នៅជាប់ក្នុងខ្លួនមនុស្សគឺសភាវគតិនេះហើយដែលបណ្តាលឱ្យមនុស្សប្រព្រឹត្តតាមសភាវគតិនេះ។

គ្រីស្ទានយើងមិនគាំទ្រគំនិតទាំងនេះទេ។ យើងត្រូវតែអានព្រះគម្ពីរដើម្បីឱ្យយល់បានច្បាស់ពីប្រភពអំពើបាបនិងដើមចមដែលនាំឱ្យមនុស្សមានបាប។ ខាងក្រោមនេះមានសេចក្តីបង្រៀនរបស់ព្រះគម្ពីរស្តីពីប្រភពនិងដើមហេតុនៃអំពើបាប។

## *សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរចំពោះប្រភពនិងដើមហេតុនៃអំពើបាប*

- ព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ថា ព្រះទ្រង់មិនដែលធ្វើបាបសោះ ហើយទ្រង់ក៏មិនដែលនាំឱ្យមានអំពើបាបដែរ (យ៉ាកុប ១:១៣)។ ប្រសិនបើយើងធ្វើបាប តែបែរទៅបន្ទោសព្រះវិញ នោះជាការប្រមាថយ៉ាងធ្ងន់ណាស់ដល់ព្រះអង្គ (ចោទិយកថា ៣២:៤)។
- ព្រះគម្ពីរបានបញ្ជាក់ថា នៅលើលោកនេះ មានតែព្រះអង្គមួយប៉ុណ្ណោះ ដែលមានអំណាចដ៏មហិមា គ្មានអំណាចណាផ្សេងទៀត ស្មើទៅនឹងព្រះអង្គឡើយ ទោះជាអំណាចរបស់អារក្សសាតាំងក៏ដោយ ហើយពិភពលោកនេះក៏មិនមែនជាសមរភូមិប្រយុទ្ធនៃអំណាចស្មើគ្នា រវាងអំណាចល្អ និងអំណាចអាក្រក់ ពន្លឺនិងភាពងងឹតនោះទេ។ ដូច្នេះយើងមិនអាចគិតថា អំពើបាបបណ្តាលមកពីចំបាំងនៃអំណាចស្មើគ្នា រវាងអំណាចនៃសេចក្តីល្អ និងអំណាចនៃសេចក្តីអាក្រក់ឡើយ។
- អ័ដាម និងអេវ៉ា ជាមនុស្សដំបូងដែលព្រះបានបង្កើតមកហើយមុនដំបូងគេគ្មានបាបទាល់តែសោះ។ នេះមិនមែនមានន័យថា ពួកគេគ្មានសមត្ថភាពក្នុងការប្រព្រឹត្តអំពើបាបនោះទេ។ តាមពិតពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបាប ដ្បិតក្រោយមកយើងឃើញថា ពួកគេបានធ្វើបាប។
- ដោយព្រោះតែព្រះបានបង្កើតយើងឱ្យដូចរូបអង្គទ្រង់ ទើបយើងមានសមត្ថភាពធ្វើបាប ព្រមទាំងដឹងខុសត្រូវផង។ ចំពោះសត្វវិញគ្មានទេ ហេតុនេះហើយវាមិនចេះធ្វើបាបទេ ហើយវាក៏គ្មានសមត្ថភាពធ្វើបាបដែរ។ យើងមាន ចំណេះដែលអាចវាយតំលៃអ្វីត្រូវ និងអ្វីខុស ដូច្នេះហើយយើងមានសមត្ថភាពប្រព្រឹត្តការដែលប្រឆាំងនិងអ្វីដែលត្រូវនោះផងដែរ។ យើងមានទំនួលខុសត្រូវដែលព្រះអង្គបានប្រទានអោយ គឺត្រូវតែគោរពស្តាប់បង្គាប់ទ្រង់ ព្រមទាំងទទួលខុសត្រូវនៅចំពោះមុខទ្រង់ផងដែរ។ ម្យ៉ាងទៀតមនុស្ស អាចមានអនុស្សាវរីយ៍ចំពោះអ្វីដែលបានកន្លងហួសទៅហើយ ព្រមទាំងអាចជ្រើសរើសទទួលយកឬមិនទទួលយកនូវអនុស្សាវរីយ៍នោះ មានន័យថា មនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការ

បដិសេធន៍ចោលនូវអ្វីៗដែលធ្លាប់មានពីមុនមក។ យើងមានសមត្ថភាពអាចស្រមើស្រមៃចង់មានអ្វីៗគ្រប់យ៉ាងដែលយើងគ្មាន រួមទាំងដៃគូរស្នេហាថ្មីផង ដែលការរវើរវាយនេះនាំមនុស្សឱ្យចេះលួច ប្រព្រឹត្តសេចក្តីកំផិត និងអំពើបាបផ្សេងៗទៀត។

- ❖ យើងមិនគ្រាន់តែមានសមត្ថភាពប៉ុណ្ណោះ លើសពីនេះទៅទៀតយើងមានឱកាសផងដែរ។ ប្រសិនបើនៅលើលោកនេះមានតែយើងម្នាក់ឯង នោះយើងក៏គ្មានឱកាសប្រព្រឹត្តឃាតកម្មដែរ។ ដូច្នេះរបស់ល្អៗជាច្រើនដែលព្រះអង្គបង្កើតមកសំរាប់សំរួលក្នុងការរស់នៅរបស់យើង របស់ទាំងនោះបែរជាផ្តល់ឱកាសឱ្យយើងប្រព្រឹត្តអំពើបាបទៅវិញ។
- ❖ ព្រះអង្គប្រទានឱ្យយើងមានបំណងចិត្ត ហើយបំណងចិត្តនោះមិនមែនជាអំពើបាបទេ ប៉ុន្តែនៅពេលយើងប្រើបំណងចិត្តនេះក្នុងផ្លូវអាក្រក់ នោះជាអំពើបាបហើយ។ ឧទាហរណ៍ ព្រះអង្គប្រទានឱ្យយើងមានតម្រេកតណ្ហា ដូច្នេះការដែលមានតម្រេកតណ្ហារវាងប្តីប្រពន្ធនោះមិនរាប់ថាជាអំពើបាបទេ តែប្រសិនបើមានតម្រេកផ្ទុយពីព្រំដែននេះ នោះជាអំពើបាបហើយ។ម្យ៉ាងទៀតការស្រេកឃ្លានអាហារចង់បានអារហារបរិភោគ វាជាការល្អ វាជាច្បាប់ធម្មជាតិ។ តែត្រូវប្រយ័ត្នចំពោះចំណង់នេះដ្បិតអ្នកខ្លះក្លាយជាមនុស្សល្មោភឬលោភលន់ អាត្មានិយមឬប្រព្រឹត្តអំពើចោរកម្ម។ល។ ដោយសារភាពសម្បូរសប្បាយហួសហេតុឬដោយសាភាពទុរគតក្នុងជីវភាពរស់នៅ។
- ❖ ពេលខ្លះសេចក្តីល្បួងមកពីមជ្ឈដ្ឋានដែលនៅជុំវិញយើង ដូចជាសេចក្តីល្បួងដែលកើតមានចំពោះអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន។ យើងនឹងលើកយកចំនុចខ្លីៗនៃសេចក្តីល្បួងរបស់អ្នកទាំងពីរមកពិចារណា ដ្បិតយើងប្រព្រឹត្តអំពើបាបក៏ដោយសារ សេចក្តីល្បួងទាំងនេះដែរ។ លោកុប្បត្តិ ៣ បានលើកឡើងពីសត្វពស់ជាសត្វចេះឧបាយកលលើសជាងអស់ទាំងសត្វព្រៃដែលព្រះអង្គបានបង្កើតមក វាប្រើភាពឆ្លាតវៃរបស់វាក្នុងការបោកបញ្ឆោតនាងអេវ៉ា ដោយប្រើពាក្យលួងលោមកុហកនិងប្រើសេចក្តីពិតតែពាក់កណ្តាល។ ដំបូងវាបានធ្វើឱ្យនាងអេវ៉ាមានចិត្តមន្ទិលសង្ស័យចំពោះព្រះបន្ទូលព្រះអង្គដោយសួរថា"តើព្រះពិតជាមានបន្ទូល?" បន្ទាប់មកវាបានក្លែងបន្លំព្រះបន្ទូលព្រះដោយនិយាយថា "តើព្រះមានបន្ទូលហាមមិនឱ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ?" (លោកុប្បត្តិ ៣:១)។ សូមធ្វើការសង្កេតពាក្យឱ្យបានច្បាស់ ពាក្យដែលសត្វពស់និយាយគឺមិនមែនជាអ្វីដែលព្រះអង្គបានមានបន្ទូលទេ។ តាមពិតព្រះអង្គបានមានបន្ទូលយ៉ាងនេះថា "ពួកគេអាចបរិភោគផ្លែឈើទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត លើកលេងតែ មួយប៉ុណ្ណោះ" ។ សត្វពស់បានក្លែងបន្លំការផ្តត់ផ្គង់របស់ព្រះអង្គនិងព្រះបន្ទូលរបស់ទ្រង់ ឱ្យមើលទៅហាក់ដូចជាមានភាពធ្ងន់ធ្ងរ, ព្រៃផ្សៃណាស់ដែលតាមការពិតមិនមែនសោះឡើយ។ ទីបំផុតសត្វពស់ក៏ក្លែងបន្លំព្រះបន្ទូលព្រះ។ ខណៈនោះយើងឃើញថានាងអេវ៉ាក៏មានអារម្មណ៍ថាអ្វីដែលសត្វពស់និយាយមិនត្រឹមត្រូវដែរ តែសត្វពស់នៅតែនិយាយបន្តទៀតហើយវាបែរជាទៅបង្ខូចព្រះឫទ័យ បំណងចិត្តដ៏បរិសុទ្ធរបស់ព្រះអង្គឱ្យមើលទៅហាក់ដូចជាអាក្រក់មិនបរិសុទ្ធទាល់តែសោះ។ ពេលនោះនាងអេវ៉ាស្មានថាខ្លួនមានសិទ្ធិអំណាចដោយផ្ទាល់ក្នុងការសំរេចយកអ្វីជាត្រូវ អ្វីជាល្អ ជាជាងទុកចិត្តលើព្រះបន្ទូលរបស់ព្រះអង្គដែលមានបន្ទូលមកកាន់នាងពីអ្វីដែលល្អ ពីអ្វីដែលពិតប្រាកដ។ សត្វពស់បានបញ្ឆោតនាងអេវ៉ាដោយធ្វើឱ្យនាងបរិភោគផ្លែឈើមួយដើមដែលទ្រង់បានហាមផ្តាច់មិនឱ្យបរិភោគ។ ដូច្នេះ ការស្មានរបស់នាងក្នុងការសំរេចយកអ្វីដែលល្អ អ្វីដែលត្រឹមត្រូវ ធ្វើឱ្យនាងចាញ់បោកពស់ ធ្វើឱ្យនាងក្លាយជាអ្នកប្រឆាំងនិងព្រះជាម្ចាស់។
- ❖ ដូច្នេះ យើងឃើញថាសេចក្តីល្បួងរបស់អ័ដាមនិងនាងអេវ៉ាមកពីមជ្ឈដ្ឋានខាងក្រៅ ប៉ុន្តែពួកគេក៏មិនអាចដោះសានៅចំពោះព្រះអង្គបានដែរ។ ព្រះអង្គមិនបានទទួលការដោះសារបស់លោកអ័ដាមនិងនាងអេវ៉ាទេ ទោះបីជាអ្វីៗដែលពួកគេនិយាយសុទ្ធតែជាការពិតក៏ដោយ។ ដូចជារឿងបរិភោគផ្លែឈើ នាងអេវ៉ាបានបរិភោគផ្លែឈើពីព្រោះតែចាញ់បោកសត្វពស់ហើយនាងក៏បានឱ្យផ្លែឈើនោះទៅអ័ដាមបរិភោគដែរ។ ពេលដែលព្រះអង្គសួរពីដើមហេតុអ្វីទើបពួកគេហ៊ានបេះផ្លែឈើដែលបានហាមនោះមកបរិភោគ អ័ដាមបានដោះសាថា ស្ត្រីបានឱ្យផ្លែឈើនោះមកទូលបង្គំបរិភោគ (លោកុ

ប្បត្តិ ៣:១២), ឯអេវ៉ាឆ្លើយដោះសាថា សត្វពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់ (លោកុប្បត្តិ ៣:១៣), អ្នកទាំងពីរ យើងមើលទៅហាក់ដូចជាមិនមានកំហុសអ្វីទេ ប៉ុន្តែពួកគេពិតជាមានទោសគឺព្រះអង្គបានរាប់ពួកគេថាជាមនុស្សមានទោសហើយពួកគេត្រូវទទួលខុសត្រូវអំពើបាបនេះនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ទៀតផង។ សូមសង្កេតមើលព្រះយេស៊ូវគ្រីស្ទ ព្រះអង្គក៏បានទទួលរងនូវសេចក្ដីល្បួងមកពីមជ្ឈដ្ឋានខាងក្រៅដែរ តែព្រះអង្គមិនបានធ្លាក់ទៅក្នុងសេចក្ដីល្បួងនោះឡើយ។

- អ្វីដែលបានកត់សំគាល់ខាងលើយើងឃើញថា អំពើបាបដែលបានកើតឡើងចំពោះអ័ដាមនិងអេវ៉ា ជាឧទាហរណ៍ឬជាគំរូមួយ ចំពោះអំពើបាបរបស់យើង។ សព្វថ្ងៃនេះ មានមនុស្សជាច្រើនក៏បានចាញ់បោកបញ្ឆោតអារក្សសាតាំងដែរ គឺវាបន្ទរក្លែងបន្លំព្រះអង្គ ព្រះបន្ទូលទ្រង់និងបន្ទុះបង្អាប់ព្រះអង្គផង។ មនុស្សនៅតែបន្តទុកចិត្តលើខ្លួនឯងក្នុងការសំរេចនូវអ្វីជាការត្រឹមត្រូវនិងពិតប្រាកដ។ ដូច្នេះ រាល់សកម្មភាពនិងឥរិយាមាយាទរបស់យើងត្រូវទទួលខុសត្រូវនូវចំពោះការជំនុំជំរះរបស់ព្រះអង្គដូចអ័ដាមនិងនាងអេវ៉ាដែរ។
- មានអ្នកខ្លះគិតថា ដំណើររឿងរបស់លោកអ័ដាមនិងនាងអេវ៉ា គ្រាន់តែជាឧទាហរណ៍មួយ ពិពណ៌នាអំពីជីវិតរបស់យើងប៉ុណ្ណោះ។ ហើយពួកគេក៏ជឿថា ទង្វើរបស់អ្នកទាំងពីរ មិនមានលទ្ធផលអ្វីដល់យើងដែរ។ តាមពិត បាបរបស់អ្នកទាំងពីរ មិនគ្រាន់តែជាគំរូមួយដែលពណ៌នាអំពីយើងប៉ុណ្ណោះទេ តែវាមានឥទ្ធិពលយ៉ាងខ្លាំងមកដល់ជីវិតរបស់យើងដូចមានចែងក្នុងព្រះគម្ពីររ៉ូម ៥:១២-២១។ ព្រះគម្ពីរបានចែងថា បាបនិងសេចក្ដីស្លាប់បានចូលក្នុងលោកិយនេះតាមរយៈអ័ដាមហើយចាប់តាំងពីពេលនោះមកលោកិយនេះក៏បានផ្លាស់ប្តូរទាំងស្រុង។ ១ពង្សាវតារក្សត្រ. ៨:៤៦, ទំនុក. ១៤៣:២, សាស្តា ៧:២០, រ៉ូម ៣:២៣ បានបង្ហាញយ៉ាងច្បាស់ថា តាំងពីជំនាន់អ័ដាមនិងអេវ៉ាមកមនុស្សទាំងអស់ លើកលែងតែព្រះអម្ចាស់យេស៊ូវគ្រីស្ទចេញ សុទ្ធតែបះបោរប្រឆាំងនិងព្រះជាម្ចាស់ទាំងអស់ ដ្បិតពួកគេស្គាល់ទ្រង់ តែមិនបានតម្កើងទ្រង់ទុកជាព្រះទេ ហេតុនោះបានជាព្រះអង្គបានប្រគល់គេទៅឯសេចក្ដីស្មោកគ្រោក តាមចិត្តគេប្រាថ្នាចង់បាន (រ៉ូម ១:២១-២៥)។

សេចក្ដីបង្រៀនដែលបានដកស្រង់ចេញពីព្រះគម្ពីរ បានបង្ហាញឱ្យឃើញថាអ្នកដឹកនាំពួកជំនុំដំបូងមួយរូបឈ្មោះ ភីឡាហ្គីស (*Pelagius*) មានការយល់ខុសឆ្គងពីអំពើបាប។ គំនិតខុសឆ្គងរបស់គាត់បានធ្វើឱ្យមានវាទប្បដិវាទយ៉ាងខ្លាំងក្នុងពួកជំនុំ។ លោកបានបង្រៀនថា អំពើបាបរបស់អ័ដាម មិនមានលទ្ធផលអីចំពោះមនុស្សជំនាន់ក្រោយទេ ហើយថា ព្រះអង្គបានបង្កើតអ័ដាមមកក្នុងសីលធម៌អព្យាក្រិត (*morally neutral*) គឺមិនល្អហើយក៏មិនអាក្រក់ដែរ ហើយទោះជាមនុស្សបច្ចុប្បន្នក៏កើតមកក្នុងសីលធម៌អព្យាក្រិតនេះក៏ដោយ ហើយក៏មិនមានអ្នកណាម្នាក់ដែលកើតមកក្នុងអំពើបាបនោះដែរ ប៉ុន្តែគ្រប់គ្នាបានកើតមកក្នុងសេរីភាពពេញទីគឺចង់ធ្វើល្អក៏បាន ចង់ធ្វើអាក្រក់ក៏បាន។ ដូច្នេះហើយអំពើបាបរបស់អ័ដាមមិនមានឥទ្ធិពលអ្វីមកដល់មនុស្សជំនាន់ក្រោយឡើយ។ សរុបមក ការបង្រៀនរបស់ *ភីឡាហ្គីស* មានលក្ខណៈខុសស្រឡះពីអ្វីដែលយើងសង្កេតឃើញក្នុងព្រះគម្ពីរ។ ដូច្នេះពួកជំនុំក៏បានបដិសេធន៍ចោលសេចក្ដីបង្រៀនរបស់លោក ដែលបានប្រកាសដោយក្រុមប្រឹក្សា ខាថាច (*Council of Carthage*)នៅឆ្នាំ ៤១៨ និងដោយក្រុមប្រឹក្សាអេភេសូរ (*Council of Ephesus*)នៅឆ្នាំ ៤៣១។

ឧទាហរណ៍ នៅក្នុងបឹងទឹកមិនហូរទេ ប៉ុន្តែនៅក្នុងទន្លេទឹកហូរមែន។ ប្រសិនបើអ្នកដាក់ដំបងឈើនៅក្នុងបឹងមួយវាមិនផ្លាស់ទីឬអាចផ្លាស់ទីយឺតក្នុងទិសដៅណាតាមខ្យល់។ ប្រសិនបើអ្នកដាក់ឈើមួយនៅក្នុងទន្លេវានឹងតាមលំហូរនៃទឹក។ វាមិនអាចទៅផ្ទុយនឹងការហូរនេះបានលុះត្រាតែមាននរណាម្នាក់រុញវាប្រឆាំងនឹងការហូរនេះ។ មនុស្សប្រៀបដូចជាដំបងក្នុងទន្លេ។ យើងបានតាមអំពើបាបហើយយើងមិនអាចទៅប្រឆាំងនឹងបាបបានទេលុះត្រាតែព្រះជួយយើង។

❖ ឥឡូវនេះមនុស្សកំពុងតែរស់នៅក្នុងអំពើបាប (រ៉ូម ៧:១៤-២០, អេភេសូរ ២:១-៣, ៤:១៧-១៩, ទីតុស ១:១៥-១៦)។ មនុស្សធ្វើបាបពីព្រោះមនុស្សមាននិស្ស័យបាប។

❖ នៅពេលដែលយើងធ្វើការសិក្សាពី " និស្ស័យបាប " យើងសង្កេតឃើញថា បាបកើតចេញពីមជ្ឈដ្ឋានក្នុងខ្លួនយើង (*within*)ទៅវិញទេ។ សេចក្តីល្បួងមកពីខាងក្រៅ តែអំពើបាបកើតចេញពីខាងក្នុងខ្លួនយើងវិញ។ ព្រះគម្ពីរបានចាត់ទុកថាចិត្ត (*heart*) ជាសំខាន់បំផុតនៅក្នុងជីវិតរបស់យើង។ ចិត្ត គឺជាសរីរាង្គនៃការគិត អារម្មណ៍ និងគោលបំណង។ ជាមួយគ្នានេះ ព្រះគម្ពីរបានបង្រៀនថា អំពើបាបកើតចេញពីចិត្ត ដែលជាចំនុចស្នូលក្នុងជីវិតរបស់យើង។ ចាប់តាំងពីជំនាន់លោកអ័ដាមនិងនាងអេវ៉ាមក ចិត្តរបស់មនុស្សបានប្រែជាខូចអាក្រក់ ហើយពេញដោយទង្វើអាក្រក់គ្រប់យ៉ាង គំនិតខូចអាក្រក់ក៏កើតចេញពីចិត្តនេះដែរ (សុភាសិត ៤:២៣, យេរេមា ១៧:៩, ម៉ាថាយ ១៥:១៩, លូកា ៦:៤៥)។ ទោះបីយ៉ាងណាក៏ដោយ ក៏បញ្ហាដែលចោទសួរថា ហេតុអីបានជាបាបអាចចូលមកក្នុងលោកិយនេះបាន ហើយហេតុអ្វីបានជាព្រះដ៏មានចេស្តាព្រះដ៏បរិសុទ្ធបានអនុញ្ញាតឱ្យការនេះកើតឡើងបាន ដែលជាការស្ថិតក្នុងភាពអាថ៌កំបាំងនៅឡើយ។

## *ទស្សនៈផ្សេងៗស្តីពីអំពើបាបនាំឱ្យមានគំនិតផ្សេងៗសំរាប់ដោះស្រាយអំពើបាប*

អ្នកខ្លះអាចមានសំនួរថា តើការដែលយល់ពីប្រភព និងពីដើមហេតុនៃអំពើបាបមានសារៈសំខាន់អ្វី? ចំលើយគឺ វាពិតជាមានសារៈសំខាន់មែន ពីព្រោះថា អ្វីដែលមនុស្សម្នាក់ជឿថាជាដើមហេតុនៃអំពើបាប នោះគេនឹងដោះស្រាយឱ្យចំនិងបញ្ហានោះ។ រឿងនេះវាមិនខុសគ្នាពីវេជ្ជបណ្ឌិតព្យាបាលអ្នកជំងឺនោះទេ។ ការព្យាបាលរបស់គាត់ វាអាស្រ័យទៅលើអ្វីដែលអ្នកជំងឺនោះឈឺ។ ប្រសិនបើគេជឿថា អំពើបាបមកដោយសាបញ្ហាសេដ្ឋកិច្ច ភាពអយុត្តិធម៌ នោះគេនឹងដោះស្រាយដោយយកបញ្ហាទាំងពីរមកសិក្សា កែតំរូវឡើងវិញ ដែលការទាំងនេះ ពួកម៉ាក្សនិយម បានជឿហើយក៏ព្យាយាមសិក្សាដោះស្រាយ ប៉ុន្តែនៅតែបរាជ័យ។ ប្រសិនបើគេមានជំនឿថា វិញ្ញាណអាក្រក់ជាអ្នកដែលធ្វើឱ្យមានអំពើបាប នោះគេនឹងដោះស្រាយឬព្យាបាលដោយប្រើវិជ្ជាមន្តអាគមដេញវិញ្ញាណនោះចេញ។ ប៉ុន្តែប្រសិនបើគេជឿថា អំពើបាប គឺជាការដែលប្រឆាំងនិងព្រះជាម្ចាស់ ហើយវាកើតចេញពីនិស្ស័យបាបរបស់យើង នោះគេយល់ថាមនុស្សមិនមានសមត្ថភាពក្នុងការដោះស្រាយដែរ។ ប៉ុន្តែយើងនៅមានសង្ឃឹម ដ្បិតយើងមានព្រះយេស៊ូវគ្រីស្ទ ទ្រង់បានចេញមុខ ដោះស្រាយបញ្ហានេះនៅក្នុងដំណឹងល្អ។ ដូច្នេះ មានតែនៅក្នុងដំណឹងល្អតែមួយគត់ប៉ុណ្ណោះ ដែលអាចដោះស្រាយអំពើបាបនេះបាន ហើយយើងត្រូវយល់ដំណឹងល្អ និងស្គាល់ពីភាពចាំបាច់នៃដំណឹងល្អនេះ។ ដូច្នេះការយល់ពីអំពើបាបបានត្រឹមត្រូវ នឹងជួយយើងឱ្យយល់ពីដំណឹងល្អបានត្រឹមត្រូវដែរ ឬក៏អាចនិយាយម្យ៉ាងទៀតបានថា ការដែលយល់យ៉ាងត្រឹមត្រូវពីដំណឹងល្អ នឹងនាំយើងឱ្យយល់បានត្រឹមត្រូវពីបាប។

**សំនួរ**

ហេតុអ្វីបានជាការយល់អំពីប្រភពនិងហេតុដែលនាំអោយមានអំពើបាបមានសារៈសំខាន់ណាស់?